អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៤ ខែឧសភា ឆ្នាំ ២០២០

# សេចក្តីប្រកាសព័ត៌មាន
# ពីសហព្រះរាជអាជ្ញាអន្តរជាតិ

ផ្អែកតាមវិធាន៥៤ នៃវិធានផ្ទៃក្នុង អ.វ.ត.ក Brenda J. Hollis ចេញសេចក្តីថ្លែងការណ៍ជាសាធារណៈនេះ ដែលពន្យល់អំពីស្ថានភាពបច្ចុប្បន្ននៃរឿងក្តីនានាដែលនៅសេសសល់នៅចំពោះមុខ អ.វ.ត.ក។

ជាការឆ្លើយតបទៅនឹងសេចក្តីប្រកាសព័ត៌មានថ្មីៗនេះ ស្តីពីការរីកចម្រើននៃរឿងក្តីនានានៅតុលាការនេះ ខ្ញុំសូមឆ្លៀតយកឱកាសនេះផ្តល់បច្ចុប្បន្នភាពអំពីសកម្មភាពតុលាការដែលកំពុងបន្ត។ រឿងក្តីនានាដែលនៅសេសសល់គឺបណ្តឹងសាទុក្ខទៅកាន់អង្គជំនុំជម្រះតុលាការកំពូលប្រឆាំងនឹងការផ្តន្ទាទោស និងការកាត់ទោស ខៀវ សំផន ក្នុងសំណុំរឿង ០០២/២ និងសារណានានាក្នុងដំណាក់កាលមុនការជំនុំជម្រះក្នុងរឿងក្តីប្រឆាំងនឹង អោ អាន (សំណុំរឿង ០០៤/២) មាស មុត (សំណុំរឿង ០០៣) និង យឹម ទិត្យ (សំណុំរឿង ០០៤) ដើម្បីសម្រេចថាតើរឿងក្តីទាំងអស់នេះគួរបញ្ជូនទៅជំនុំជម្រះ ឬត្រូវលើកលែងចោទប្រកាន់។

ដំណើរការតាមផ្លូវតុលាការកំពុងតែដំណើរការនៅក្នុងរឿងក្តីទាំងអស់នេះ។ ខៀវ សំផន បានប្តឹងសាទុក្ខប្រឆាំងនឹងការផ្តន្ទាទោសរបស់គាត់ក្នុងសំណុំរឿង ០០២/២ - ជាការជំនុំជម្រះលើកទីពីរប្រឆាំងនឹង ខៀវ សំផន និង នួន ជា ដែលក្នុងនោះពួកគេទាំងពីរត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ក្នុងឆ្នាំ២០១៨។ សហព្រះរាជអាជ្ញានាពេលបច្ចុប្បន្ននេះ កំពុងរៀបចំចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខនោះ។ បន្ទាប់ពីសារណាជាលាយលក្ខណ៍អក្សរទាំងអស់ត្រូវបានដាក់ ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលនឹងសម្រេច ថាតើត្រូវមានអំណះអំណាងផ្ទាល់មាត់ចំពោះរឿងក្តីនេះឬទេ មុនពេលខ្លួនពិចារណាលើបណ្តឹងសាទុក្ខនេះ។ ក្រោយពីមរណភាពរបស់ នួន ជា ក្នុងខែសីហា ឆ្នាំ២០១៩ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ត្រូវបានរលត់ ហើយការផ្តន្ទាទោសរបស់គាត់ត្រូវបានរក្សាទុក។

រឿងក្តីចំនួនបីដែលនៅដំណាក់មុនការជំនុំជម្រះបច្ចុប្បន្ននេះ គឺស្ថិតក្នុងដំណាក់កាលខុសៗគ្នា នៃដំណើរការតុលាការ។ អង្គបុរេជំនុំជម្រះបានធ្វើការសន្និដ្ឋានរបស់ខ្លួនលើរឿងក្តី អោ អាន នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។ ចៅក្រមទាំងប្រាំរូបនៅអង្គបុរេជំនុំជម្រះ បានឯកភាពលើក្របខណ្ឌជាមូលដ្ឋានរបស់ អ.វ.ត.ក សម្រាប់ការសម្រេចសេចក្តី

លើរឿងក្តី ក្នុងករណីដែលអង្គជំនុំជម្រះនេះបរាជ័យមិនអាចឈានដល់សេចក្តីសម្រេចដោយសំឡេងភាគច្រើនលើសលុបបាន។ គឺមានន័យថា ប្រសិនបើយ៉ាងហោចណាស់ចៅក្រមបួនរូបក្នុងចំណោមចៅក្រមទាំងប្រាំរូប មិនអាចឯកភាពគ្នាលើការសម្រេចសេចក្តីនោះទេ រឿងក្តីនោះនឹងត្រូវបន្តទៅមុខទៀត។ ចៅក្រមនៃអង្គបុរេជំនុំជម្រះមិនអាចរកបាននូវសំឡេងភាគច្រើនលើសលុប សម្រាប់ការសម្រេចសេចក្តីនៃរឿងក្តីនេះទេ ដោយសារចៅក្រមបីរូបបានកំណត់ថា រឿងក្តីនេះគួរត្រូវបានលើកលែងចោទប្រកាន់ ចំណែកចៅក្រមពីររូបទៀតបានកំណត់ថា រឿងក្តី អោ អាន គួរបន្តទៅជំនុំជម្រះ។ ទោះបីជាសំណើផ្លូវការរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ផ្អែកលើក្របខណ្ឌច្បាប់ជាមូលដ្ឋានរបស់តុលាការនេះយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូង មិនបានចាត់វិធានការផ្លូវការណាមួយលើរឿងក្តីនេះទេមកទល់ពេលនេះ។ ស្របតាមអាណត្តិរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិបានសម្រេចថា ភាពនៅស្ងៀមរបស់អង្គជំនុំជម្រះសាលាដំបូងបង្កើតបានជាការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ នេះ ដែលរូបគាត់កំពុងប្តឹងសាទុក្ខទៅកាន់អង្គជំនុំជម្រះតុលាការកំពូល ដែលជាអង្គជំនុំជម្រះតុលាការខ្ពស់បំផុតនៅក្នុងតុលាការនេះ។ បណ្តឹងសាទុក្ខនេះនឹងត្រូវដាក់នៅថ្ងៃទី៤ ខែឧសភា។

រឿងក្តី មាស មុត និង យឹម ទិត្យ បច្ចុប្បន្ននេះ កំពុងតែស្ថិតនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ អង្គជំនុំជម្រះនេះបានស្តាប់អំណះអំណាងផ្ទាល់មាត់ក្នុងរឿងក្តី មាស មុត ក្នុងខែវិច្ឆិកា ឆ្នាំមុន ហើយពេលនេះកំពុងពិភាក្សាលើផ្នែកសម្រេចសេចក្តីនៃរឿងក្តីនោះ។ ចំណែកគូភាគីបានបញ្ចប់សារណារបស់ខ្លួននៅក្នុងរឿងក្តី យឹម ទិត្យ នេះហើយ និងកំពុងរង់ចាំសេចក្តីសម្រេចថាតើ នឹងមានអំណះអំណាងផ្ទាល់មាត់ដែរឬអត់ មុនពេលអង្គបុរេជំនុំជម្រះពិចារណាលើផ្នែកសម្រេចសេចក្តីនៃរឿងក្តីនោះ។

ជាការសំខាន់ដែលយើងត្រូវរម្លឹកថា រដ្ឋាភិបាល និងអង្គនីតិប្រតិបត្តិរបស់កម្ពុជា និងអង្គការសហប្រជាជាតិ បានបង្កើតក្របខណ្ឌច្បាប់មួយដើម្បីធានាថា អ.វ.ត.ក បំពេញកិច្ចក្នុងនាមស្ថាប័នតុលាការឯករាជ្យ និងមិនលំអៀង សម្រេចសេចក្តីលើករណីនានានៅចំពោះមុខខ្លួន ដោយផ្អែកលើក្របខណ្ឌច្បាប់ ច្បាប់ជាធរមាន និងអង្គហេតុនៃរឿងក្តីនីមួយៗ។ អាស្រ័យដោយមូលហេតុនេះ ចៅក្រម និងព្រះរាជអាជ្ញា មានអាណត្តិត្រូវបំពេញកិច្ចដោយឯករាជ្យ ផ្អែកតាមការយល់របស់ខ្លួនចំពោះក្របខណ្ឌច្បាប់របស់តុលាការ ព្រមទាំងច្បាប់ និងអង្គហេតុនៃរឿងក្តីនីមួយៗ ដោយចាកផុតពីឥទ្ធិពលខាងក្រៅ។ យ៉ាងណាមិញក្នុងន័យល្អ ការប៉ុនប៉ង ឬការព្យាយាមពីមជ្ឈដ្ឋានខាងក្រៅតុលាការណាមួយ ដើម្បីផ្លាស់ប្តូរលទ្ធផល ឬដើម្បីរំលត់រឿងក្តីណាមួយនៅចំពោះតុលាការ តាមមធ្យោបាយណាមួយក្រៅពីដំណើរការតាមផ្លូវតុលាការជាផ្លូវការ អាចនឹងត្រូវបានពិចារណាថា ជាការជ្រៀតជ្រែកពីខាងក្រៅដែលត្រូវបានហាមឃាត់។

មកដល់ថ្ងៃនេះ តុលាការបានបំពេញកាតព្វកិច្ចរបស់ខ្លួនដោយឯករាជ្យ និងមិនលំអៀង ទាក់ទងនឹងការសម្រេចសេចក្តីរបស់តុលាការជាស្ថាពរ ក្នុងករណីប្រឆាំងនឹង ឌុច (សំណុំរឿង ០០១) និងរឿងក្តីទីមួយប្រឆាំងនឹង នួន ជា និង ខៀវ សំផន (សំណុំរឿង ០០២/១)។ យើងសង្ឃឹមថា តុលាការនឹងបន្តរក្សាឯករាជ្យភាពរបស់តុលាការរបស់ខ្លួនជាបន្តទៀត ហើយសម្រេចសេចក្តីលើករណីដែលនៅសេសសល់ តាមរយៈដំណើរការតុលាការដែលត្រឹម

ត្រូវយុត្តិធម៌ មិនលំអៀង និងមានតម្លាភាព ដោយផ្អែកលើតែក្របខណ្ឌច្បាប់របស់តុលាការ ច្បាប់ជាធរមាន និងអង្គហេតុនៃរឿងក្តីនីមួយៗប៉ុណ្ណោះ។ ក្នុងនាមសហព្រះរាជអាជ្ញាអន្តរជាតិ ខ្ញុំទទួលយកថា វាជាកាតព្វកិច្ចរបស់ខ្ញុំក្នុងការស្វែងរកវិធានការនានាដែលអាចរកបានទាំងអស់ ដើម្បីធ្វើយ៉ាងណាទទួលបានការសម្រេចសេចក្តីដូច្នេះចំពោះរឿងក្តីទាំងនេះ៕

## សេចក្តីប្រកាសព័ត៌មានពីសហព្រះរាជអាជ្ញាជាតិ

## ទាក់ទងនឹងជនត្រូវចោទ អោ អាន ក្នុងសំណុំរឿងលេខ០០៤/២

ផ្អែកតាមវិធាន៥៤ នៃវិធានផ្ទៃក្នុង អ.វ.ត.ក សហព្រះរាជអាជ្ញាជាតិ លោកស្រី ជា លាង សូមធ្វើសេចក្តីប្រកាសជាសាធារណៈពាក់ព័ន្ធនឹងការវិវត្តថ្មីៗនៃសំណុំរឿងលេខ៖០០៤/២ ដែលមានជនត្រូវចោទ **អោ អាន** ៖

កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះ បានចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ដែលសហព្រះរាជអាជ្ញាជាតិប្តឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចំណែកឯ សហព្រះរាជអាជ្ញាអន្តរជាតិប្តឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់)។

កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីថ្លែងការណ៍ពាក់ព័ន្ធនឹងជនត្រូវចោទ **អោ អាន** ក្នុងសំណុំរឿងលេខ៖០០៤/២ ដោយបានបញ្ជាក់ថា៖ អង្គជំនុំជម្រះសាលាដំបូងមិនដែរបានទទួលការជូនដំណឹងជាផ្លូវការអំពីសំណុំរឿងនេះទេ ហើយក៏មិនបានទទួលសំណុំរឿងនេះឡើយ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ឯកសារសម្ភារៈភាគច្រើនក្នុងសំណុំរឿងនេះ គឺជាឯកសារសម្ងាត់ ហើយជាបញ្ហាសាធាតុដែលអង្គជំនុំជម្រះសាលាដំបូង ពុំមានសិទ្ធិចូលមើលឯកសារសម្ភារៈទាំងនោះឡើយ មានន័យថា មិនអាចចូលមើលសំណុំរឿងនេះបានឡើយ។

អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថា រហូតមកដល់ពេលនេះ សំណុំរឿងនេះកំពុងស្ថិតនៅក្នុងសមត្ថកិច្ចរបស់អង្គបុរេជំនុំជម្រះ ហើយអង្គបុរេជំនុំជម្រះក៏មិនទាន់បានបញ្ជូនសំណុំរឿងនេះមកអង្គជំនុំជម្រះសាលាដំបូងដែរ ចាប់តាំងពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ដែលអង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួន។

ចៅក្រមជាតិនៃអង្គជំនុំជម្រះសាលាដំបូង ជឿជាក់ថា សំណុំរឿងនេះត្រូវបានបិទបញ្ចប់នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង ពុំមានសិទ្ធិអំណាចណាមួយក្នុងការធ្វើសេចក្តីសម្រេចក្នុងសំណុំរឿងនេះឡើយ ហើយក៏មិនមានការជំនុំជម្រះជនត្រូវចោទ **អោ អាន** ក្នុងសំណុំរឿងលេខ៖០០៤/២ នេះដែរ នៅពេលបច្ចុប្បន្ន ឬនាពេលអនាគត។

សហព្រះរាជអាជ្ញាជាតិ យល់ស្របជាមួយនឹងចៅក្រមជាតិនៃអង្គជំនុំជម្រះសាលាដំបូង ដែលថា សំណុំរឿងលេខ៖០០៤/២ ពាក់ព័ន្ធនឹងជនត្រូវចោទ **អោ អាន** បានបិទបញ្ចប់នៅចំពោះមុខអង្គបុរេជំនុំជម្រះរួចហើយ ហើយក៏ពុំមានភាពចាំបាច់សម្រាប់សហព្រះរាជអាជ្ញាជាតិក្នុងការធ្វើសកម្មភាពណាមួយឡើយ៕